**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៤៦ អនក្រ.បក.

# អនុក្រឹត្យ
## ស្តីពី
## ការទទួលស្គាល់សមាជិក និងសមាសភាពការិយាល័យប្រតិបត្តិ សម្រាប់សភាពាណិជ្ជកម្មកម្ពុជា អាណត្តិទី២

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសភាពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៦/០២២ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្ម មាត្រា២ និងមាត្រា១៥ ស្តីពីច្បាប់សភាពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ៨៩ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០២ ស្តីពីការបង្កើតសភាពាណិជ្ជកម្មកម្ពុជា

-បានឃើញអនុក្រឹត្យលេខ០៧ អនក្រ.បក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៧ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់សភាពាណិជ្ជកម្មកម្ពុជា

-បានឃើញអនុក្រឹត្យលេខ២៩ អនក្រ.បក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៧ ស្តីពីការកែសម្រួល មាត្រា៦ មាត្រា៩ និងមាត្រា១២ នៃអនុក្រឹត្យលេខ០៧ អនក្រ.បក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៧ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់សភាពាណិជ្ជកម្មកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សម្រេច

**មាត្រា១.** ទទួលស្គាល់សមាជិកសភាពាណិជ្ជកម្មកម្ពុជា ចំនួន ២៨រូប ដូចខាងក្រោម ៖

| | |
|---|---|
| ១-អ្នកឧកញ៉ា **គិត ម៉េង** | ២- ឯកឧត្តម **ប៊ុន ឆុន** |
| ៣- ឯកឧត្តម **លី អ៊ុងលី** | ៤- ឯកឧត្តម **សុខ សុខ** |
| ៥- ឯកឧត្តម **លឹម ប៊ុនសេង** | ៦- ឧកញ៉ា **តូ ពុយ** |
| ៧- ឧកញ៉ា **ណាំ ស្រ៊ុន** | ៨- ឧកញ៉ា **អោន ម៉ាឌី** |
| ៩- ឧកញ៉ា **ឱុយ តី** | ១០- ជំទាវ **អ៊ឹង ស៊ីវតានសុគន្ធារី** |
| ១១- លោក **ហាក់ សុចវណ្ណា** | ១២- លោក **ឈុន ធំ** |
| ១៣-ឯកឧត្តមឧកញ៉ា **ឡាច ម៉េងឃីន** | ១៤-ឯកឧត្តមឧកញ៉ា **លី យ៉ុងផាត់** |
| ១៥-ឯកឧត្តមឧកញ៉ា **ស៊ីន សុខណា** | ១៦-ឯកឧត្តមឧកញ៉ា **ស៊ីច ថៃ** |
| ១៧-ឯកឧត្តមឧកញ៉ា **លឹម ប៊ុនហេង** | ១៨-លោកស្រីឧកញ៉ា **ចាន់ សុទ្ធា** |
| ១៩-ជំទាវឧកញ៉ា **លីម ឈីចហួ** | ២០-ជំទាវឧកញ៉ា **កែច ម៉ាលី** |
| ២១-ឧកញ៉ា **ហាន់ ឃាង** | ២២-ឧកញ៉ា **យ៉ាំ ស៊ុយសាំង** |
| ២៣-ឧកញ៉ា **លឹម ហេង** | ២៤-ឯកឧត្តម **ហ៊ី បាទី** |
| ២៥-ឧកញ៉ា **លី យុងផៃ** | ២៦-លោក **ខៀវ ចេងហេង** |
| ២៧-ឯកឧត្តមឧកញ៉ា **គិត ខៀង** | ២៨-ឧកញ៉ា **ឆី ពិសិដ្ឋ** |

**មាត្រា២.** ទទួលស្គាល់អ្នកឧកញ៉ា **គិត ម៉េង** ជាប្រធានសភាពាណិជ្ជកម្មកម្ពុជា។

**មាត្រា៣.** ទទួលស្គាល់សមាសភាពការិយាល័យប្រតិបត្តិរបស់សភាពាណិជ្ជកម្មកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| ១-អ្នកឧកញ៉ា **គិត ម៉េង** | ជាប្រធាន |
| ២- ឯកឧត្តម **ប៊ុន ឆុន** | ជាអនុប្រធាន |
| ៣- ឯកឧត្តម **លី អ៊ុងលី** | ជាអនុប្រធាន |
| ៤- ឯកឧត្តម **សុខ សុខ** | ជាអនុប្រធាន |
| ៥- ឯកឧត្តម **លឹម ប៊ុនសេង** | ជាអនុប្រធាន |
| ៦- ឧកញ៉ា **តូ ពុយ** | ជាអនុប្រធាន |
| ៧- ឧកញ៉ា **អោន ម៉ាឌី** | ជាអនុប្រធាន |
| ៨- ឧកញ៉ា **ឱុយ តី** | ជាអនុប្រធាន |
| ៩- ឧកញ៉ា **ណាំ ស្រ៊ុន** | ជាអនុប្រធាន |
| ១០- ជំទាវ **អ៊ឹង ស៊ីវតានសុគន្ធារី** | ជាអនុប្រធាន |
| ១១- លោក **ហាក់ សុចវណ្ណា** | ជាអនុប្រធាន |
| ១២- លោក **ឈុន ធំ** | ជាអនុប្រធាន |
| ១៣-ឯកឧត្តមឧកញ៉ា **ឡាច ម៉េងឃីន** | ជាអនុប្រធាន |
| ១៤-ឯកឧត្តមឧកញ៉ា **លី យ៉ុងផាត់** | ជាអនុប្រធាន |
| ១៥-ឯកឧត្តមឧកញ៉ា **ស៊ីន សុខណា** | ជាអនុប្រធាន |
| ១៦-ឯកឧត្តមឧកញ៉ា **ស៊ីច ថៃ** | ជាអនុប្រធាន |
| ១៧-ឯកឧត្តមឧកញ៉ា **លឹម ប៊ុនហេង** | ជាអនុប្រធាន |
| ១៨-លោកស្រីឧកញ៉ា **ចាន់ សុទ្ធា** | ជាអនុប្រធាន |

| | |
|---|---|
| ១៩-ជំទាវឧកញ៉ា **លឹម ឈីវហូ** | ជាអនុប្រធាន |
| ២០-ជំទាវឧកញ៉ា **កែវ ម៉ាលី** | ជាអនុប្រធាន |
| ២១-ឧកញ៉ា **ហាន់ ឃាង** | ជាអនុប្រធាន |
| ២២-ឧកញ៉ា **យ៉ាំ ស៊ុយសាំង** | ជាអនុប្រធាន |
| ២៣-ឧកញ៉ា **លឹម ហេង** | ជាអនុប្រធាន |
| ២៤-ឯកឧត្តម **ហ៊ី បាវី** | ជាអនុប្រធាន |
| ២៥-ឧកញ៉ា **លី យុងថៃ** | ជាអនុប្រធាន |
| ២៦-លោក **ឡៀប ចេងហេង** | ជាអនុប្រធាន |
| ២៧-ឯកឧត្តមឧកញ៉ា **គិត ឡៀង** | ជាហេរញ្ញិក |
| ២៨-ឧកញ៉ា **ឆី ពិសិដ្ឋ** | ជាលេខាធិការ |

**មាត្រា៤.** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៥.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ប្រធានសភាពាណិជ្ជកម្មកម្ពុជា និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ មាត្រា២ និងមាត្រា៣ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី**

ដើម្បីសុំចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- សាលារាជធានី-ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ